## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្ត សៀមរាប

-សំណុំរឿងរដ្ឋប្បវេណីលេខ : ១៨៦
ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៩
-ឈ្មោះរឿងក្តី : ប្តឹងសុំលែងលះ
-សាលក្រមលេខ : ៣៦ " ច "
ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៩

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

បានធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នៅបន្ទប់សវនាការលេខ ០២
បានដំណើរការនីតិវិធីទាញហេតុផលផ្ទាល់មាត់នៅថ្ងៃសុក្រ ១កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣ ត្រូវនឹងថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩ វេលាព្រឹក។
បានបញ្ចប់នីតិវិធីទាញហេតុផលផ្ទាល់មាត់នៅថ្ងៃសុក្រ ១កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣ ត្រូវនឹងថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៩ វេលាព្រឹក។
កាលបរិច្ឆេទប្រកាសនៅថ្ងៃព្រហស្បតិ៍ ៦រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៩ វេលា រសៀល ។

### ចៅក្រមជំនុំជម្រះ

លោក [redacted] ចៅក្រមនៃសាលាដំបូង ខេត្តសៀមរាប ។

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជីនៃសាលាដំបូង ខេត្តសៀមរាប ។

-ដើមចោទឈ្មោះ [redacted] ឃីន ភេទស្រី កើតថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៨២ សញ្ជាតិ ខ្មែរ អាសយដ្ឋានបច្ចុប្បន្ននៅ [redacted] ។ មានលោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិ

-ចុងចម្លើយឈ្មោះ [redacted] ហ្វាយ ភេទប្រុស កើតថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៨០ សញ្ជាតិ ខ្មែរ អាសយដ្ឋានបច្ចុប្បន្ន [redacted] ។ មានលោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិ

### អង្គហេតុ និង ចំណុចវិវាទ :

**ក - សាលក្រមទាមទារដោយគូភាគី :**

ដើមចោទទាមទារឱ្យសាលាដំបូងខេត្តសៀមរាប ចេញសាលក្រមសម្រេចដូចតទៅ :

១.ឲ្យដើមចោទឈ្មោះ [redacted] ឃីន បានលែងលះពីចុងចម្លើយឈ្មោះ [redacted] ហ្វាយ។

២.ឲ្យដើមចោទសុំសិទ្ធិគ្រប់គ្រងលើកូនចំនួនពីរនាក់មានឈ្មោះ [redacted] សានលី ភេទស្រី កើតថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៧ និងឈ្មោះ [redacted] សម្បត្តិ ភេទប្រុស កើតថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៤។

៣.ឲ្យចុងចម្លើយឈ្មោះ [redacted] ហ្វាយ បង់ថ្លៃអាហារកាតព្វកិច្ចចិញ្ចឹមកូនផ្ដាច់ចំនួន ២០.០០០$ (ពីរម៉ឺនដុល្លារអាមេរិក)។

៤.បែងចែកទ្រព្យសម្បត្តិរួមមាន៖

ក.ដើមចោទទាមទារគ្រប់គ្រង និងចាត់ចែងលើ ដី និងផ្ទះមួយកន្លែង មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ 17100602-2889 ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ស្ថិតនៅភូមិខ្នារ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប។

ខ.ដើមចោទទាមទារគ្រប់គ្រង និងចាត់ចែងលើសាឡុងឈើបែងមួយឈុត។

គ.ប្រគល់ដី និងផ្ទះ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ 171006002-3006 ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ស្ថិតនៅភូមិខ្នារ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប។

ឃ.ប្រគល់តុបាយចំនួន ០១ និងកៅអីតុកតា ចំនួន ០៨ គ្រាប់ ឲ្យទៅចុងចម្លើយ។

ង.បែងចែកជាពីរចំណែកស្មើគ្នានូវ ម៉ូតូមួយគ្រឿងម៉ាកហុងដាឌ្រីម ផលិតឆ្នាំ២០១៤ ពណ៌ខៀវ និងកាមេរ៉ាថតរូបម៉ាកកាណុង ០៧គ្រឿង និងម៉ាកនីកុង ចំនួន ០២ គ្រឿង ដែលមាននៅក្នុងហាងលក់ដូរ ស្ថិតនៅភូមិសាលាកំរើក សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប។

៥.បែងចែកបំណុលរួមជាពីរចំណែកស្មើគ្នារួមមាន៖

ក.ប្រាក់ជំពាក់ឪពុកម្ដាយរបស់ដើមចោទចំនួន ៧.៥០០$ (ប្រាំពីរពាន់ប្រាំរយ)ដុល្លារអាមេរិក។

ខ.ប្រាក់ជំពាក់ឈ្មោះ [redacted] ថាយ និងប្រពន្ធឈ្មោះ [redacted] យីងហ្វុង ចំនួន ៨.០០០$ (ប្រាំបីពាន់ដុល្លារអាមេរិក)។

៦.ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

<u>ខ-ការពន្យល់ត្រួសៗអំពីដំណើររឿងក្ដី :</u>

ដើមចោទ និងចុងចម្លើយបានរៀបការជាមួយគ្នានៅថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០០៥ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៦ នៅមន្ត្រីអត្រានុកូលដ្ឋានឃុំដំដែក។ ក្រោយពីដើមចោទ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា គឺមានកូនពីរនាក់ កូនទី១ឈ្មោះ [redacted] សានលី ភេទស្រី កើតថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៧ និងកូនទី២ឈ្មោះ [redacted] សម្បត្តិ ភេទប្រុស កើតថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៤ ព្រមទាំងទ្រព្យសម្បត្តិ និងបំណុលរួមដូចក្នុងកម្មវត្ថុនៃបណ្ដឹង។ បច្ចុប្បន្នដោយសារចុងចម្លើយតែងតែហូបស្រា និងប្រើហិង្សាមកលើដើមចោទ ជេរប្រមាថ ប្រចណ្ឌគ្មានមូលហេតុ ហើយជួនកាលបិទទ្វារមិនឲ្យដើមចោទចូលផ្ទះ ជាហេតុធ្វើឲ្យដើមចោទអស់មនោសញ្ចេតនាក្នុងរស់នៅជាមួយចុងចម្លើយតទៅទៀត។

គ-<u>ការថ្លែងការណ៍របស់គូភាគី:</u>

**អ្នកតំណាងដោយអាណត្តិរបស់ដើមចោទបានធ្វើសេចក្ដីថ្លែងការណ៍ថា៖** កូនក្ដីខ្លួនសូមរក្សាការទាមទារ និងសេចក្ដីថ្លែងការណ៍ដូចនៅក្នុងសេចក្ដីថ្លែងការណ៍ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៩ ទុកដដែល។

**អ្នកតំណាងដោយអាណត្តិរបស់ចុងចម្លើយបានធ្វើសេចក្ដីថ្លែងការណ៍តបវិញថា៖** ខ្លួនសុំរក្សាអះអាងដែលមានក្នុងសេចក្ដីថ្លែងការណ៍តប ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩ និងដូចនៅក្នុងកំណត់ហេតុស្ដីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៩ និងសុំសំណូមពរលោកចៅក្រមសម្រេចតាមនីតិវិធី។



Scanned with CamScanner

ការពិនិត្យភស្តុតាងៈ

-ការសាកសួរភាគីៈ

**ដើមចោទបានអះអាងថាៈ** ខ្លួនសុំលែងលះពីចុងចម្លើយដោយមូលហេតុថា ការរស់នៅជាមួយគ្នាមិនចុះសម្រុង ចុងចម្លើយបិទសិទ្ធិសេរីភាពខ្លួន ហើយគាត់តែងតែញ៉ាំស្រាស្រវឹងបង្កជាបញ្ហារហូត ដំបូងខ្លួននៅផ្ទះមិនបានចេញទៅធ្វើការទេ គាត់ចេះតែប្រចណ្ឌរករឿងហើយមិនអោយខ្លួនកាន់លុយទេ ពេលខ្លួនចង់បានអ្វីត្រូវលាដៃសុំពីគាត់។ ពេលគ្រួសារខ្លួនមានកម្មវិធីគាត់មិនដែលទៅហើយបើខ្លួនទៅពេលត្រលប់មកវិញដឹងតែគាត់រករឿង។ ដល់ពេលខ្លួនចេញធ្វើការហើយមកដល់ផ្ទះយឺតតិចតួច គឺគាត់រករឿងបិទទ្វារមិនឲ្យខ្លួនចូលផ្ទះ និងចោទថាខ្លួនមានប្រុស។

**ចុងចម្លើយបានអះអាងថាៈ** រឿងហេតុដំបូង គឺថ្ងៃហូបស៊ុបជុំគ្នា ដើមចោទនិងគ្រួសារបានប្រើហិង្សាមកលើខ្លួន ហើយខ្លួនបានដាក់ ពាក្យបណ្ដឹងទៅប៉ុស្តិ៍ ហើយក៏មានការសម្របសម្រួលធ្វើកិច្ចសន្យាឈប់ប្រើហិង្សាមកលើខ្លួនទៀត។ លុះដល់១០ថ្ងៃក្រោយ ថ្ងៃនោះខ្លួនផឹកស្រាអស់ប្រាំមួយកំប៉ុងហើយឡើងទៅសំរាន្តនៅជាន់លើហើយគាត់ជិះម៉ូតូចេញពីធ្វើការមកដល់គាត់ហៅខ្លួននិងអង្រួនទ្វារខ្លាំងមែនទែន ខ្លួនឮនឹងប្រុងចុះមកបើធ្វើឲ្យដែរតែគាត់ស្រែកថាបើហែងមិនបើកអញប្ដឹងប៉ូលីស ហើយមានឡានប៉ូលីសមួយក្រុមមកនិងផ្លោះរបងចូលទៅបើកទ្វារផ្ទះ។ ប្រពន្ធខ្លួនមានជម្ងឺឈាមសស៊ីឈាមក្រហម ហើយខ្លួនបានបញ្ជូនទៅព្យាបាលនៅប្រទេសវៀតណាម ដោយខ្លួនបានខ្ចីប្រាក់ពីបងស្រីខ្លួនប្រហែល៧០០០$ទៅ៨០០០$ សរុបទាំងអស់ជាងមួយម៉ឺនដុល្លារ ព្រោះគាត់ឈឺខ្លួនចេះតែខ្ចីបន្តៗរហូតទៅ ខ្លួនមិនដែលឲ្យគាត់ធ្វើការធ្ងន់ទេសូម្បីខោអាវក៏មិនដែលឲ្យគក់ដែរគឺខ្លួនជាអ្នកគក់។ អោយតែពេលឈ្លោះគ្នាគាត់តែងតែនាំកូនខ្លួនរត់ទៅនៅជាមួយម្ដាយគាត់ឯដំដែកបង្ខាំងទុកជិតមួយខែ ដើម្បីអោយខ្លួនទៅអង្វរមិនតិចជាង៣០ដង។

**ដើមចោទបានអះអាងថាៈ** បើខ្លួនបានធ្វើដូចគាត់លើកឡើង យកកូនទៅបង្ខាំងមែនខ្លួនសុំឲ្យតុលាការសួរកូន ព្រោះកូនក៏ដឹងរឿងម៉ែឪនៅក្នុងផ្ទះដែរ ហើយចំពោះការលើកឡើងពីការខ្ចីប្រាក់បងស្រីគាត់ខ្លួនសុំឲ្យកោះហៅបងស្រីគាត់មកសួរតទល់គ្នា ហើយមុននឹងឆ្លើយសុំឲ្យផឹកទឹកសម្បថទាំងអស់គ្នា ខ្លួនសុខចិត្តព្រោះខ្លួននិយាយអ្វីជាការពិត អ្វីដែលខ្លួនអត់ដឹងខ្លួនមិនទទួល។ គាត់មិនឲ្យកូនមកព្រោះគាត់ដឹងថាកូនត្រូវតាមខ្លួន។ ខ្លួនមានប្រាក់ខែពីបួនរយទៅប្រាំរយដុល្លារជាង ខ្លួនចេះភាសាចិន ខ្លួនមានពេលវេលាគ្រប់គ្រាន់ម៉ោងការងារខ្លួនគឺអាស្រ័យលើខ្លួនឯង ព្រោះខ្លួនត្រូវអនឡាយទៅប្រទេសចិនផ្ទាល់។ ពីមុនខ្លួនឈឺ តែឥឡូវខ្លួនជាហើយ ពេលទៅព្យាបាលនៅវៀតណាម ពេលខ្លះគាត់អ្នកជូនទៅ តែភាគច្រើនខ្លួនទៅម្នាក់ឯង ចំណាយម្ដងៗមិនទៀង ប្រហែល ៣០០ដុល្លារ។

**ចុងចម្លើយបានថ្លែងថាៈ** ខ្លួនទាមទារសិទ្ធិអំណាចមេបាលើកូនទាំងពីរនាក់ ហើយចំពោះអាហារកាតព្វកិច្ច គឺសុំឲ្យដើមចោទផ្ដល់តាមលទ្ធភាព។ ហើយគាត់ (ដើមចោទ) ចុះចេញយកទ្រព្យសម្បត្តិមួយចំនួនទៀតរួមមាន ម៉ាស៊ីនត្រជាក់មួយ កង្ហារបីគ្រឿង ចង្ក្រានហ្គាសចំនួន ០១គ្រឿង និងគ្រឿងអលង្ការដែលមានតម្លៃប្រហែលជា ២.០០០ $ (ពីរពាន់ដុល្លារអាមេរិក) ជាទ្រព្យរួមក្នុងចំណងដៃអាពាហ៍ពិពាហ៍ ទ្រព្យទាំងអស់ខ្លួនសុំឲ្យលក់ចែកគ្នាម្នាក់ពាក់កណ្ដាល។ ខ្លួននៅភូមិខ្នារ សង្កាត់ជ្រាវ ម្ដាយខ្លួននៅភ្នំពេញ បច្ចុប្បន្នកូនកំពុងរស់នៅជាមួយឪពុកម្ដាយខ្លួននៅភ្នំពេញ។

<u>ការសួរសាក្សី</u>

កូនស្រីឈ្មោះ [redacted]សានលី បានឆ្លើយថាៈ ខ្លួនអាយុ១២ឆ្នាំ ខ្លួនចូលរៀនវិញថ្នាក់ទី៧ ខ្លួនរៀននៅ



Scanned with CamScanner

សាលាសុវណ្ណភូមិ។ ខ្លួនចង់នៅជាមួយម៉ាក់ ដោយសារខ្លួនស្រលាញ់ម៉ាក់ និងត្រូវការភាពកក់ក្ដៅ ហើយគាត់ក៏អាចចិញ្ចឹមខ្លួនបានដែរ ខ្លួនមានតែម៉ាក់ក៏បានដែរ ចំណែកប៉ាគាត់ផឹកស្រា ហើយខ្លាចគាត់ប្រើហិង្សា គាត់ធ្លាប់វាយ។ ខ្លួនសម្រេចចិត្តដោយមិនមានការបង្ខិតបង្ខំទេ។

សាក្សីឈ្មោះ [redacted] វណ្ណ បានឆ្លើយថា៖ ខ្លួនត្រូវជាបងចុងចម្លើយ ខ្លួនដឹងរឿងខ្ចីលុយប្អូនស្រីខ្លួនឈ្មោះ [redacted] ឡុន អស់ជាងមួយម៉ឺន ខ្លួនដឹងតែមួយម៉ឺនជាងតែមិនដឹងមួយម៉ឺនប៉ុន្មានទេ ឮថាខ្ចីយកទៅព្យាបាលប្រពន្ធ ពេលទៅខ្ចីខ្លួននៅនឹងទីនោះដែរ ខ្លួនឃើញហុយលុយតែមិនដឹងប៉ុន្មានទេ។ រឿងប្ដីប្រពន្ធគេខ្លួនមិនដឹងទេ។ អត់មានធ្វើក្រដាសស្នាមទេព្រោះជាបងប្អូន។

សាក្សីឈ្មោះ [redacted] ហ្សុង បានឆ្លើយថា៖ ថ្ងៃកើតរឿងនោះខ្លួនធ្វើស៊ុប ក៏ហើយគេមានរឿងអីទេ គេក៏ឈ្លោះគ្នាឈ្លោះរឿងកូនខ្លួនធ្វើការ ថាធ្វើការ គឺធ្វើខ្ញុំគេ ហើយក៏មានការទាស់គ្នា និងប្រតាយប្រតប់គ្នា ខ្លួនបានចូលទៅឃាត់បំបែក។ ពួកគាត់ជំពាក់ខ្លួន ៧៥០០ដុល្លារអាមេរិក ដោយឃើញកូនទាស់គ្នាពេកសួរទៅថាជំពាក់អង្គការ ខ្លួនឲ្យកូនខ្ចីទៅដោះអង្គការទៅកុំឲ្យកូនទាស់គ្នា។

សាក្សីឈ្មោះ [redacted] យឹងហ្សុង បានឆ្លើយថា៖ ខ្លួនដឹងថាប្ដីប្រពន្ធគេឧស្សាហ៍ទាស់ទែងគ្នា។ ពួកគាត់បានខ្ចីលុយខ្លួនថាយកទៅធ្វើផ្ទះនៅ ដំបូងខ្ចី១០០០០$ (មួយម៉ឺនដុល្លារអាមេរិក) ក្រោយមក៣០០០$ (បីពាន់ដុល្លារអាមេរិក) តែគាត់បានសងអស់ ៥០០០$ (ប្រាំពាន់ដុល្លារអាមេរិក)ហើយ នៅសល់តែ ៨០០០$ (ប្រាំបីពាន់ដុល្លារអាមេរិក)។

សាក្សីឈ្មោះ [redacted] ខាន់ បានឆ្លើយថា៖ ខ្ចីខ្លួនចំនួន ៧៥០០$ (ប្រាំពីរពាន់ប្រាំរយដុល្លារអាមេរិក)។ កូនខ្លួនមិនទៅរកស៊ីវាថាដេកតែស៊ី ដល់ចេញធ្វើការវាប្រចណ្ឌ ផឹកស្រាស្រវឹង គឺរករឿងជេរប្រមាថ។

អ្នកតំណាងដោយអាណត្តិរបស់ដើមចោទបានធ្វើសេចក្ដីថ្លែងការណ៍ថា៖ ពាក់ព័ន្ធរឿងនេះខ្លួនសុំរក្សាការទាមទារ និងសេចក្ដីថ្លែងការណ៍ដដែល ទាក់ទងនឹងការកំណត់អំណាចមេបាលើកូន តាមការពិនិត្យភស្តុតាងតាមការសាកសួរភាគី គឺដើមចោទមានលទ្ធភាព និងពេលវេលាគ្រប់គ្រាន់ ម្យ៉ាងទៀតទាក់ទងនឹងកូននេះ គឺតុលាការបានឲ្យចុងចម្លើយនាំកូនមកសវនាការដើម្បីសួរកូន តែគាត់មិនព្រមយកកូនមក ដែលនេះបញ្ជាក់ឲ្យឃើញថាគាត់ខ្លាចថាបើយកកូនមកកូននឹងតាមម្ដាយ ទាក់ទងនឹងចុងចម្លើយផ្អែកតាមចម្លើយរបស់ចុងចម្លើយគឺគាត់ពិសារម្ដង៥ទៅ៦កំប៉ុង ដែលបញ្ជាក់ថាគាត់ជាមនុស្សចូលចិត្តផឹកស្រា ដែលអាចពិបាកទប់អារម្មណ៍ក្នុងការប្រើហិង្សា ហើយកូនដែលមានវត្តមាននៅសវនាការនេះ ក៏បានឆ្លើយដែរថានៅជាមួយម្ដាយ ព្រោះមានតែម្ដាយទេដែលអាចផ្ដល់ភាពកក់ក្ដៅឲ្យខ្លួនបាន ចំណែកឪពុកចូលចិត្តផឹកស្រា ហើយប្រើហិង្សា។ ចំពោះអាហារកាតព្វកិច្ច បើសម្រេចឲ្យម្ដាយជាអ្នកអំណាចមេបា ឪពុកដែលគ្មានអំណាចមេបាត្រូវផ្ដល់អាហារកាតព្វកិច្ច។ ទាក់ទងនឹងទ្រព្យរួមដែលចុងចម្លើយលើកឡើង គឺចុងចម្លើយមិនបានដាក់បណ្ដឹងតប និងមានភស្តុតាងណាមួយមកបញ្ជាក់ឡើយ ចំណែកបំណុលរួមដែលជំពាក់ឪពុកម្ដាយ និងម្ដាយមីងដើមចោទ គឺនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺចុងចម្លើយបានទទួលស្គាល់រួចហើយ ដោយឡែកចំពោះបំណុលដែលចុងចម្លើយលើកឡើង គឺពុំមានឯកសារបញ្ជាក់នោះទេ ហេតុនេះសុំឲ្យតុលាការធ្វើការពិចារណា និងសម្រេចតាមការទាមទាររបស់ដើមចោទ។

អ្នកតំណាងដោយអាណត្តិរបស់ចុងចម្លើយបានធ្វើសេចក្ដីថ្លែងការណ៍ថា៖ ខ្លួនសុំបន្ថែមខ្លះទាក់ទង នឹងការទាមទារសិទ្ធិចិញ្ចឹមកូន កូនក្ដីខ្លួនទាមទារសិទ្ធិចិញ្ចឹមកូនទាំងពីរ ព្រោះកូនក្ដីខ្លួនមានមុខរបរជាជាងជួសជុលកាមេរ៉ានៅក្នុងក្រុងសៀមរាប ហើយគាត់ជាអ្នកទំនុកបំរុងគ្រួសារតាំងពីដើមមក គាត់ជាមេគ្រួសារដែលល្អ ចំពោះថ្លៃសាលាកូន គឺកូនក្ដីខ្លួនជាបង់ ចំពោះអាហារកាតព្វកិច្ច គឺកូនក្ដីខ្លួនសុំច្រានចោល ទី១.ព្រោះចំណូលរបស់គាត់គឺសម្រាប់ផ្គត់ផ្គង់

ជីវភាពប្រចាំថ្ងៃ ព្រោះគាត់នៅទីនេះតែម្នាក់ឯង បងប្អូនសាច់ញាតិ គឺនៅភ្នំពេញទាំងអស់ ទី៣ គាត់ជាអ្នកផ្គត់ផ្គង់ការសិក្សារបស់កូនឈ្មោះ [redacted] សម្បត្តិ ដែលកំពុងរៀននៅសាលាឯកជនមួយថ្លៃគួរសម។ ចំពោះទ្រព្យសម្បត្តិរួមកូនក្តីខ្លួននៅតែទាមទារលក់ទាំងអស់ ហើយចែកជាពីរចំណែកស្មើគ្នា ចំណែកបំណុលរួមជំពាក់ឪពុកម្តាយដើមចោទចំនួន ៧៥០០$ កូនក្តីខ្លួនទទួលស្គាល់ និងជំពាក់សាក្សីឈ្មោះ [redacted] យីង ហ្វង ចំនួន ១៣០០០$ តែសងអស់ ៥០០០$ នៅសល់ ៨០០០$ ក៏កូនក្តីខ្លួនទទួលស្គាល់ដែរ និងបំណុលជំពាក់បងស្រីកូនក្តីខ្លួន ចំនួន ១៨០០០$ ដែលមានសាក្សីឈ្មោះ ចៅវណ្ណ ថាមានបញ្ជាក់ហើយថាបានខ្ចីម្តងបន្តិចៗរហូតដល់ ១៨០០០$។

អ្នកតំណាងដោយអាណត្តិរបស់ដើមចោទបានធ្វើសេចក្តីថ្លែងការតបថា៖ ចំពោះសិទ្ធិអំណាចមេបា គឺអ្នកតំណាងដោយអាណត្តិរបស់ចុងចម្លើយបានថ្លែងហើយថាចុងចម្លើយមានការលំបាក ដោយចំណូលបានត្រឹមតែផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃតែប៉ុណ្ណោះ ប្រសិនបើគាត់យកកូនទាំងពីរទៅគ្រប់គ្រងនោះកាន់តែលំបាក ចំណែកកូនក្តីខ្លួន គឺបានអះអាងហើយថាគាត់មានចំណូលច្បាស់លាស់ពី៤០០$ ទៅ៥០០$ ហើយគាត់មានធ្វើទីផ្សារជាមួយចិន ព្រោះគាត់ចេះភាសាចិន ម្យ៉ាងទៀត មួយទៀតពាក់ព័ន្ធនឹងកូនបើចុងចម្លើយ គឺចុងចម្លើយមិនបានគ្រប់គ្រងកូនដោយផ្ទាល់ទេ គឺចុងចម្លើយយកទៅឲ្យរស់នៅជាមួយជីដូនដែលនៅភ្នំពេញ ចំណែកចុងចម្លើយគឺរស់នៅសៀមរាប ហេតុនេះមិនអាចផ្តល់ភាពកក់ក្តៅឲ្យកូន ហើយកូនបែកបងប្អូន ហេតុនេះគ្មានផលល្អប្រសើរដល់កូននោះទេ មួយទៀតដើមចោទបានបញ្ជាក់ថាកូនទៅនៅជាមួយជីដូន និងអ៊ុំ គឺមានការធ្វើបាន ម្យ៉ាងទៀតកូនក៏បានបញ្ជាក់ដែរថាចុងចម្លើយជាមនុស្សចូលចិត្តផឹកស្រា និងប្រើហិង្សា ហេតុនេះដើម្បីជាផលប្រយោជន៍កូន កុំឲ្យប៉ះពាល់ដល់សតិអារម្មណ៍កូនខ្លួនសុំឲ្យតុលាការសម្រេចតាមការទាមទាររបស់ដើមចោទ។

អ្នកតំណាងដោយអាណត្តិរបស់ចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍ថា៖ ការលើកឡើងរបស់អ្នកតំណាងដោយអាណត្តិថាមានការប្រើហិង្សាលើកូនឈ្មោះ [redacted] សម្បត្តិ នោះ គឺមិនពិតទេ គ្រាន់តែពាក្យចចាមអារ៉ាមប៉ុណ្ណោះ ព្រោះការសិក្សារបស់កូនឈ្មោះ [redacted] សម្បត្តិ គឺល្អ ហើយបានលេខមួយ ដូចមានរូបថតដាក់ជូនតុលាការស្រាប់។

**ឃ-ចំណុចវិវាទ:**

ឃ.១.ចំណុចគ្មានវិវាទ៖ ការទាមទារលែងលះ និងការទទួលបន្ទុកប្រាក់ប្រដាប់ក្តី

ឃ.២.ចំណុចមានវិវាទ៖

១.ដើមចោទសុំមានអំណាចមេបាលើកូនទាំងពីរនាក់ ចុងចម្លើយច្រានចោលដោយសុំមានអំណាចមេបាលើកូនទាំងពីរនាក់

២.ដើមចោទសុំឲ្យចុងចម្លើយបង់អាហារកាតព្វកិច្ចផ្តាច់ចំនួន ២០០០០$ (ពីរម៉ឺនដុល្លារអាមេរិក) ចុងចម្លើយច្រានចោល

៣.ការបែងចែកទ្រព្យរួម និងបំណុលរួមចំនួន ១៨០០០$ (មួយម៉ឺនប្រាំបីពាន់ដុល្លារអាមេរិក)

**សំអាងហេតុ :**

ឆ្លងតាមលទ្ធផលនៃការសាកសួរគូភាគី និងការពិនិត្យភស្តុតាងនានា នៅក្នុងកាលបរិច្ឆេទទាញហេតុផលដោយផ្ទាល់មាត់ តុលាការយល់ឃើញថា៖

**១**-ដើមចោទ និងចុងចម្លើយ ជាសហព័ទ្ធដែលមានចំណងអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានឃុំដំដែក និងមានសំបុត្រអាពាហ៍ពិពាហ៍



Scanned with CamScanner

លេខ ០៤៨ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៦។ ហេតុនេះ ពាក្យបណ្ដឹងចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៩ របស់ដើមចោទឈ្មោះ [redacted] យីន គឺមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ដែលអាចឲ្យតុលាការយកមកធ្វើការពិចារណាបាន ។

២-អ្នកតំណាងដោយអាណត្តិរបស់ដើមចោទនិងដើមចោទឈ្មោះ [redacted] យីន បានអះអាងថា ដើមចោទសុំលែងលះពីចុងចម្លើយឈ្មោះ [redacted] ហ្វាយ ដោយមូលហេតុថា ការរស់នៅជាមួយគ្នាមិនចុះ សម្រុង ចុងចម្លើយបិទសិទ្ធិសេរីភាពខ្លួន ហើយគាត់តែងតែញាំស្រាស្រវឹងបង្កជាបញ្ហារហូត ដំបូងខ្លួននៅផ្ទះមិនបានចេញទៅធ្វើការទេ គាត់ចេះតែប្រចណ្ឌរករឿងហើយមិនអោយខ្លួនកាន់លុយទេ ពេលខ្លួនចង់បានអ្វីត្រូវលាដៃសុំពីគាត់។ ពេលគ្រួសារខ្លួនមានកម្មវិធីគាត់មិនដែលទៅហើយបើខ្លួនទៅពេលត្រលប់មកវិញដឹងតែគាត់ររករឿង។ ដល់ពេលខ្លួនចេញធ្វើការហើយមកដល់ផ្ទះយឺតតិចតួច គឺគាត់រករឿងបិទទ្វារមិនឲ្យខ្លួនចូលផ្ទះ និងចោទថាខ្លួនមានប្រុស។ ការទាមទារលែងលះនេះ ភាគីចុងចម្លើយបានទទួលស្គាល់ការទាមទារ ដោយឯកភាពលែងលះជាមួយដើមចោទ ។ ហេតុនេះ ឃើញថា សហព័ទ្ធនេះរស់នៅមិនចុះសម្រុងនឹងគ្នាចេះតែរកាំរកូសគ្នា គ្មានសុភមង្គល ដើមចោទនិងចុងចម្លើយអស់មនោសញ្ចេតនាក្នុងការរួមរស់នៅជាមួយគ្នាតទៅទៀតហើយ ហើយបានព្រមព្រៀងគ្នាក្នុងការលែងលះ គោលបំណងនៃអាពាហ៍ពិពាហ៍មិនអាចបន្តទៅទៀតបាន និងមានមូលហេតុនៃការលែងលះ ស្របតាមមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី ហេតុនេះ តុលាការគប្បីធ្វើការពិចារណា និងសម្រេចតាមឆន្ទៈគូភាគី ដោយសម្រេចទទួលស្គាល់ការទាមទាររបស់ដើមចោទ ស្របតាមមាត្រា៩៧៩ នៃក្រមរដ្ឋប្បវេណី។

៣-ដើមចោទ និងចុងចម្លើយ ពិតជាបានរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមផ្លូវច្បាប់ប្រាកដមែន ដោយបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ និងមានកូនពីរនាក់ដែលសំបុត្របញ្ជាក់កំណើតលេខ ២៤៩ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១ និងសំបុត្រកំណើតលេខ ១១២ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៤ ជាភស្តុតាង ។

៤-អ្នកតំណាងដោយអាណត្តិរបស់ដើមចោទ និងដើមចោទឈ្មោះ [redacted] យីន បានអះអាងថា ខ្លួនសុំមានអំណាចមេបាលើកូន០២នាក់ ទី១ឈ្មោះ [redacted] សានលី ភេទស្រី កើតថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៨ មានសំបុត្របញ្ជាក់កំណើតលេខ ២៤៩ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ ទី២ឈ្មោះ [redacted] សម្បត្តិ ភេទប្រុស កើតថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៤ ដោយមូលហេតុថា កូនស្ថិតនៅក្នុងវ័យកុមារតូចៗដែលចាំបាច់ណាស់ត្រូវតែមានម្ដាយនៅក្បែរ ដើម្បីទំនុកបំរុង និងផ្ដល់ភាពកក់ក្ដៅដល់កូន។ ដើមចោទមានលទ្ធភាព និងសមត្ថភាព ព្រមទាំងពេលវេលាគ្រប់គ្រាន់ក្នុងការមើលថែរក្សាផ្ដល់ភាពកក់ក្ដៅ ផ្ដល់ការអប់រំ និងការសិក្សាដល់កូនសម្រាប់អនាគត។ ប្រសិនបើឲ្យចុងចម្លើយជាអ្នកមានសិទ្ធិអំណាចមេបាលើកូនទាំងពីរនាក់នោះ គឺចុងចម្លើយមិនបានគ្រប់គ្រងកូនដោយផ្ទាល់ទេ គឺចុងចម្លើយយកទៅឲ្យរស់នៅជាមួយជីដូនដែលនៅភ្នំពេញ ចំណែកចុងចម្លើយគឺរស់នៅសៀមរាប ហេតុនេះមិនអាចផ្ដល់ភាពកក់ក្ដៅឲ្យកូន ហើយកូនបែកបងប្អូន បែបនេះគ្មានផលល្អប្រសើរដល់កូននោះទេ ហើយមិនមានអ្នកណាអាចមើលថែរក្សាកូនឲ្យបានល្អប្រសើរក្រៅពីម្ដាយនោះឡើយ។ មួយទៀតដើមចោទបានបញ្ជាក់ថាកូនទៅនៅជាមួយជីដូន និងអ៊ំ គឺមានការធ្វើបាប ម្យ៉ាងទៀតកូនក៏បានបញ្ជាក់ដែរថាចុងចម្លើយជាមនុស្សចូលចិត្តផឹកស្រា និងប្រើហិង្សា ហេតុនេះដើម្បីជាផលប្រយោជន៍កូន កុំឲ្យប៉ះពាល់ដល់សតិអារម្មណ៍កូន និងផ្អែកតាមមាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ការកំណត់យកដើមចោទជាអ្នកមានសិទ្ធិអំណាចមេបាលើកូនទាំងពីរ គឺអាចឲ្យកូនទាំងពីរនាក់មានអនាគតល្អប្រសើរ ជាងការកំណត់យកចុងចម្លើយជាអ្នកមានអំណាចមេបាលើកូន។ ឃើញថាការទាមទាររបស់ដើមចោទនេះ ត្រូវបានចុងចម្លើយប្រានចោល និងទាមទារមានសិទ្ធិអំណាចមេបាលើកូនទាំងពីរនាក់វិញ ដោយមានមូលហេតុថា ខ្លួនមាន

មុខរបរជាជាងជួសជុលកាម៉េរ៉ានៅក្នុងក្រុងសៀមរាប ហើយគាត់ជាអ្នកទំនុកបំរុងគ្រួសារតាំងពីដើមមក គាត់ជាមេគ្រួសារដែលល្អ ចំពោះថ្លៃសាលាកូន គឺកូនក្តីខ្លួនជាបង់ ហើយទាក់ទងនឹងការប្រើហិង្សា គឺដើមចោទទេជាអ្នកប្រើហិង្សាមកលើខ្លួនរហូតដល់មានពាក្យបណ្តឹងនៅប៉ុស្តិ៍នគរបាលទៀតផង។

តាមមាត្រា ១០៣៧ កថាខណ្ឌ ៣ នៃក្រមរដ្ឋប្បវេណី បើការពិភាក្សាពីការសម្រេចអំពីអំណាចមេបាពុំបានសម្រេច ឬពុំអាចពិភាក្សាបាន តុលាការត្រូវកំណត់អ្នកមានអំណាចមេបា ដោយពិចារណាទៅលើផលប្រយោជន៍របស់កូន។

ឆ្លងតាមការពិនិត្យភស្តុតាងដោយការសាកសួរភាគី និងសាក្សី ឃើញថា ភាគីចុងចម្លើយអាចហូបស្រារហូតដល់ទៅ៥កំប៉ុងទៅ៦កំប៉ុង ហើយសាក្សីជាកូនស្រីឈ្មោះ [redacted] សានលី ភេទស្រី អាយុ១២ឆ្នាំ ក៏បានឆ្លើយបញ្ជាក់ដែរថា ខ្លួនចង់ទៅរស់នៅជាមួយម្តាយ ព្រោះខ្លួនត្រូវការភាពកក់ក្តៅ ហើយមានតែម្តាយទេដែលអាចផ្តល់ភាពកក់ក្តៅ និងអាចចិញ្ចឹមខ្លួនបាន ចំណែកចុងចម្លើយដែលជាឪពុក គឺតែងតែផឹកស្រា និងប្រើហិង្សាមកលើខ្លួន។ ម្យ៉ាងទៀត ចុងចម្លើយក៏បានអះអាងដែរថាខ្លួនរស់នៅខេត្តសៀមរាប តែបានយកកូនទៅរស់នៅជាមួយម្តាយរបស់ខ្លួននៅរាជធានីភ្នំពេញ ហើយអ្នកតំណាងដោយអាណត្តិរបស់ចុងចម្លើយក៏បានថ្លែងដែរថា ចំណូលរបស់ចុងចម្លើយគឺសម្រាប់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ ព្រោះគាត់នៅទីនេះតែម្នាក់ឯង បងប្អូនសាច់ញាតិ គឺនៅភ្នំពេញទាំងអស់ ចំណែកដើមចោទគឺបានបញ្ជាក់ថាខ្លួនមានចំណូលច្បាស់លាស់ដែលអាចផ្គត់ផ្គង់កូនបានល្អ។ បន្ថែមលើសពីនេះទៅទៀត តុលាការបានជូនដំណឹងឲ្យគូភាគីនាំកូនមកកាន់សវនាការ តែចុងចម្លើយមានចេតនាមិនយកមក ដែលនេះមានភាពស៊ីសង្វាក់គ្នានឹងការលើកឡើងរបស់ភាគីដើមចោទ ដែលបានលើកឡើងថា ចុងចម្លើយមិនហ៊ានយកកូនមក ព្រោះខ្លាចថាកូននឹងតាមម្តាយ។ ទន្ទឹមនឹងនេះ ចុងចម្លើយបានថ្លែងទាមទារឲ្យតុលាការលក់ទ្រព្យសម្បត្តិរួមរបស់ខ្លួនទាំងអស់រួមទាំងផ្ទះ និងដីដើម្បីយកប្រាក់មកចែកជាពីរចំណែកស្មើគ្នា ដែលបានបង្ហាញឲ្យឃើញថា ចុងចម្លើយពុំមានគិតដល់កូនៗដែលត្រូវការទីជម្រកចាំបាច់នោះទេ។ មួយវិញទៀត តុលាការយល់ឃើញថា កូនឈ្មោះ [redacted] សម្បត្តិ នៅតូចទើបតែមានអាយុ៥ឆ្នាំ ដែលត្រូវការមើលថែថ្នាក់ថ្នមផ្តល់ភាពកក់ក្តៅជាចាំបាច់ពីម្តាយ ដូចពាក្យស្លោកមួយបានពោលថា "ស៊ូស្លាប់បាកុំឲ្យស្លាប់មេ" ដូច្នេះ មានតែម្តាយទេដែលអាចផ្តល់ការមើលថែដល់កូនបានល្អជាងអ្នកណាទាំងអស់។ ដូចនេះ ដើម្បីជាផលប្រយោជន៍ដល់កុមារ តុលាការគប្បីប្រគល់កូនឈ្មោះ [redacted] សានលី ភេទស្រី កើតថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៧ និងកូនឈ្មោះ [redacted] សម្បត្តិ ភេទប្រុស កើតថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៤ ឱ្យទៅដើមចោទជាអ្នកមានអំណាចមេបា។ ហើយភាគីដែលពុំមានអំណាចមេបា មានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបាន ដោយភាគីដែលបានអំណាចមេបាត្រូវបង្កលក្ខណៈងាយស្រួលដល់ភាគីម្ខាងទៀត តាមមាត្រា ១០៤០ កថាខណ្ឌ១ និងកថាខណ្ឌ ៣ នៃក្រមរដ្ឋប្បវេណី។

**៦**-ដើមចោទទាមទារឲ្យចុងចម្លើយបង់ថ្លៃអាហារកាតព្វកិច្ចចិញ្ចឹមកូនផ្តាច់ចំនួន ២០.០០០$(ពីរម៉ឺនដុល្លារអាមេរិក) តែចុងចម្លើយប្រានចោលដោយមានមូលហេតុថាចំណូលរបស់ខ្លួនគឺសម្រាប់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ ព្រោះខ្លួននៅទីនេះតែម្នាក់ឯង បងប្អូនសាច់ញាតិ គឺនៅភ្នំពេញទាំងអស់។ ឃើញថា ការពិភាក្សាអំពីកម្រិត ឬរបៀបនៃការផ្គត់ផ្គង់អាហារកាតព្វកិច្ច ពុំអាចពិភាក្សាបានទេ ហេតុនេះ តុលាការត្រូវកំណត់ដោយគិតពិចារណាទៅសេចក្តីត្រូវការចាំបាច់ក្នុងជីវភាពរស់នៅរបស់ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច លទ្ធភាពទ្រព្យធនរបស់ជនដែលមានករណីកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច និងស្ថានភាពផ្សេងទៀតទាំងអស់ ស្របតាមមាត្រា ១១៤២ នៃក្រមរដ្ឋប្បវេណី។

៧-តាមវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០៦០២-២៨៨៩ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ២០១៨ និងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០៦០០២-៣០០៦ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ២០១៨ ព្រមទាំងការអះអាងទទួលស្គាល់របស់គូភាគី និងភស្តុតាងនានា បានបញ្ជាក់ថាដី និងផ្ទះមួយកន្លែង មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ 17100602-2889 ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ស្ថិតនៅភូមិខ្នារ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប, សាឡុងឈើបេងមួយឈុត,ដី និងផ្ទះ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ 171006002-3006 ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ស្ថិតនៅភូមិខ្នារ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប, តុបាយចំនួន ០១ និងកៅអីតុកតា ចំនួន ០៨ គ្រាប់, ម៉ូតូមួយគ្រឿងម៉ាកហុងដាឌ្រីម ផលិតឆ្នាំ២០១៤ ពណ៌ខៀវ និងកាមេរ៉ាថតរូបម៉ាកកាណុង ០៧គ្រឿង និងម៉ាកនីកុង ចំនួន ០២ គ្រឿង ដែលមាននៅក្នុងហាងលក់ដូរ ស្ថិតនៅភូមិសាលាកំរើក សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប និងបំណុលជំពាក់ឪពុកម្តាយដើមចោទចំនួន ៧៥០០$ (ប្រាំពីរពាន់ប្រាំរយដុល្លារអាមេរិក) និងជំពាក់ឈ្មោះ [redacted] យីងហ្វុង ចំនួន៨០០០$ (ប្រាំបីពាន់ដុល្លារអាមេរិក) គឺជាទ្រព្យសម្បត្តិរួមរវាងដើមចោទឈ្មោះ [redacted] យីន និងចុងចម្លើយឈ្មោះ [redacted] ហ្វាយ ក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ប្រាកដមែន។ ដោយឡែក ម៉ាស៊ីនត្រជាក់មួយ កង្ហារបីគ្រឿង ចង្ក្រានហ្គាសចំនួន ០១គ្រឿង និងគ្រឿងអលង្ការដែលមានតម្លៃប្រហែលជា ២.០០០ $ (ពីរពាន់ដុល្លារអាមេរិក) ដែលចុងចម្លើយអះអាងថាជាទ្រព្យសម្បត្តិរួមដែរនោះ ហើយត្រូវបានដើមចោទបដិសេធ គឺពុំមានភស្តុតាងណាមកបញ្ជាក់ថាជាទ្រព្យសម្បត្តិរួមរបស់ដើមចោទ និងចុងចម្លើយនោះទេ ហេតុនេះ តុលាការពុំអាចយកមកធ្វើការពិចារណាសម្រេចបែកចែកបានឡើយ។ ដូចគ្នាដែរ ចំពោះការលើកឡើងរបស់ចុងចចម្លើយអំពីបំណុលរួមបន្ថែមចំនួន ១៨០០០$ (មួយម៉ឺនប្រាំបីពាន់ដុល្លារអាមេរិក) ហើយត្រូវដើមចោទបដិសេធនោះ ឃើញថា នៅក្នុងកាលបរិច្ឆេទទាញហេតុផលដោយផ្ទាល់មាត់ តុលាការបានធ្វើការពិនិត្យភស្តុតាងតាមរយៈការសាកសួរភាគី និងអោយបំបែកសាក្សីឈ្មោះ [redacted] វណ្ណ ដែលជាសាក្សីរបស់ចុងចម្លើយចេញក្រៅ ហើយតុលាការបានធ្វើការសាកសួរភាគីចុងចម្លើយឈ្មោះ [redacted] ហ្វាយ បានឆ្លើយថា ដើមចោទមានជម្ងឺឈាមសស៊ីឈាមក្រហម ហើយខ្លួនបានបញ្ជូនទៅ ព្យាបាលនៅប្រទេសវៀតណាម ដោយខ្លួនបានខ្ចីប្រាក់ពីបងស្រីខ្លួនប្រហែល៧០០០$ ទៅ ៨០០០$ សរុបទាំងអស់ចំនួន ១៨០០០$ (មួយម៉ឺនប្រាំបីពាន់ដុល្លារអាមេរិក) ដោយខ្ចីម្តងបន្តិចៗ តែមិនបានធ្វើលិខិតស្នាមទេ។ រួចតុលាការបានធ្វើការសាកសួរសាក្សីឈ្មោះ [redacted] វណ្ណ បានឆ្លើយថាខ្លួនដឹងរឿងខ្ចីលុយប្អូនស្រីខ្លួនឈ្មោះ [redacted] ឡុន អស់ជាងមួយម៉ឺន ខ្លួនដឹងតែមួយម៉ឺនជាងតែមិនដឹងមួយម៉ឺនប៉ុន្មានទេ ឮថាខ្ចីយកទៅព្យាបាលប្រពន្ធ ពេលទៅខ្ចីខ្លួននៅនឹងទីនោះដែរ ខ្លួនឃើញហុយលុយតែមិនដឹងប៉ុន្មានទេ។ ឃើញថាចម្លើយរបស់សាក្សីឈ្មោះ [redacted] វណ្ណ នេះគឺហាក់មិនស៊ីសង្វាក់គ្នានឹងចម្លើយរបស់ចុងចម្លើយ និងមានភាពមិនច្បាស់លាស់ ដែលមិនអាចឲ្យតុលាការលើកយកមកធ្វើជាមូលដ្ឋានក្នុងការពិចារណា និងសម្រេចបាន។

៨-ការបែងចែកទ្រព្យសម្បត្តិរួម ៖

ដើមចោទឈ្មោះ [redacted] យីន ទាមទារមានសិទ្ធិគ្រប់គ្រងជាកម្មសិទ្ធិនូវទ្រព្យសម្បត្តិរួមដូចខាងក្រោម៖

-ដី និងផ្ទះមួយកន្លែង មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ 17100602-2889 ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ស្ថិតនៅភូមិខ្នារ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប។

-សាឡុងឈើបេងមួយឈុត។

និងបែងចែកជាពីរចំណែកស្មើគ្នានូវ ម៉ូតូមួយគ្រឿងម៉ាកហុងដាឌ្រីម ផលិតឆ្នាំ២០១៤ ពណ៌ខៀវ និងកាមេរ៉ាថតរូបម៉ាកកាណុង ០៧គ្រឿង និងម៉ាកនីកុង ចំនួន ០២ គ្រឿង ដែលមាននៅក្នុងហាងលក់ដូរស្ថិតនៅភូមិសាលាកំរើក សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប។

ហើយប្រគល់ឱ្យចុងចម្លើយឈ្មោះ [redacted] ហ្វាយ មានសិទ្ធិគ្រប់គ្រងជាកម្មសិទ្ធិនូវទ្រព្យសម្បត្តិរួមដូចខាងក្រោម៖

-ដី និងផ្ទះ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ 171006002-3006 ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ស្ថិតនៅភូមិខ្នារ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប។

-តុបាយចំនួន ០១ និងកៅអីតុកតា ចំនួន ០៨ គ្រាប់ ឲ្យទៅចុងចម្លើយ។

តែចុងចម្លើយបានធ្វើការច្រានចោលការទាមទារនេះ ដោយទាមទារឲ្យយកទ្រព្យទាំងអស់លក់យកប្រាក់ហើយចែកគ្នាជាពីរចំណែកស្មើគ្នា។

ដូចនេះ ឃើញថាការពិភាក្សាគ្នារវាងប្ដីប្រពន្ធពីការបែងចែកទ្រព្យសម្បត្តិរួមមិនអាចពិភាក្សាបានទេ ដូច្នេះ តុលាការត្រូវពិចារណាតាមមាត្រា ៩៨០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី។

អ្នកតំណាងដោយអាណត្តិរបស់ដើមចោទបានអះអាងថា បន្ទាប់ពីដើមចោទ និងចុងចម្លើយបានឈ្លោះទាស់នឹងគ្នា ចុងចម្លើយមិនព្រមឲ្យដើមចោទចូលទៅរស់នៅនឹងផ្ទះណាមួយឡើយ ដោយចុងចម្លើយបានបិទទ្វារផ្ទះ និងចាក់សោរផ្ទះ មិនអនុញ្ញាតឲ្យដើមចោទរស់នៅឡើយ ដើមចោទត្រូវបង្ខំចិត្តទៅរស់នៅផ្ទះរបស់ម្ដាយបង្កើត។ ការទាមទាររបស់ដើមចោទនេះ គឺដោយសារដើមចោទមានការងារនៅក្នុងខេត្តសៀមរាប ហើយត្រូវការទីជម្រក(ផ្ទះ)សម្រាប់ស្នាក់នៅរបស់ខ្លួន និងកូនជាប្រចាំថ្ងៃ។ ចំណែកសាឡុងមួយឈុត គឺដើមចោទសុំសិទ្ធិគ្រប់គ្រង និងចាត់ចែងដែរ ដោយហេតុថាដើមចោទយល់ព្រមប្រគល់ ដី និងផ្ទះ មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១៧១០០៦០០២-៣០០៦ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ មានទីតាំងនៅភូមិខ្នារ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប, តុបាយមួយ និងកៅអីកូនតុក្កតាចំនួន ០៨គ្រាប់ ឃើញថាមានភាពសមាមាត្រគ្នារវាងដើមចោទនឹងចុងចម្លើយ។ ចំណែកម៉ូតូម៉ាកហុងដាឌ្រីមផលិតឆ្នាំ២០១៤ ពណ៌ខៀវចំនួន ០១គ្រឿង និងកាមេរ៉ាថតរូប ម៉ាកកាណុងចំនួន ០៧គ្រឿង និងម៉ាកនីកុងចំនួន ០២គ្រឿង ដែលដើមចោទទាមទារឲ្យធ្វើការបែងចែក ហើយងាយស្រួលក្នុងការលក់ដើម្បីយកប្រាក់មកធ្វើការបែងចែកផងដែរ។ ចំណែកការទាមទារដែលចុងចម្លើយ ទាមទារឲ្យយកទ្រព្យសម្បត្តិទាំងអស់លក់យកប្រាក់ចែកជាពីរចំណែកស្មើគ្នា គឺមិនត្រឹមត្រូវទេ ដោយហេតុថា ទោះបីជានៅក្នុងមាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណី បានចែងថានៅក្នុងពេលលែងលះសហព័ទ្ធនីមួយៗមានសិទ្ធិក្នុងការទទួលយកនូវចំណែក ១ភាគ២ នៃទ្រព្យរួមក៏ដោយ ក៏មិនមានន័យថា ត្រូវតែលក់ទ្រព្យទាំងអស់ដើម្បីយកប្រាក់មកបែងចែកជាពីរចំណែកនោះដែរ ហើយបើសិនជាយកដី និងផ្ទះទាំងអស់ទៅលក់ គឺពិតជាត្រូវជួបនូវបញ្ហា និងមានការលំបាកលើតម្លៃនៃការលក់ដី និងផ្ទះដែលពុំត្រូវរ៉ូវគ្នារវាងដើមចោទ និងចុងចម្លើយ ហើយត្រូវប្រើរយៈពេលយូរ និងត្រូវបាត់បង់ផ្ទះដែលជាទីជម្រកប្រចាំថ្ងៃ ដោយត្រូវទៅជួលផ្ទះស្នាក់នៅដែលត្រូវចំណាយថ្លៃឈ្នួលផ្ទះ និងចំណាយផ្សេងៗដែលប៉ះពាល់ដល់ជីវភាពដើមចោទ ការស្នាក់នៅរបស់កូនៗ និងប៉ះពាល់ដល់ការរៀនសូត្ររបស់កូនៗផងដែរ។ សេចក្ដីថ្លែងការណ៍របស់អ្នកតំណាងដោយអាណត្តិដើមចោទនេះ គឺមានលក្ខណៈសមហេតុសមផល គប្បីតុលាការធ្វើការពិចារណា។



Scanned with CamScanner

តាមមាត្រា ៩៨០ កថាខណ្ឌ២ ចំណុច(ខ) នៃក្រមរដ្ឋប្បវេណី បានចែងថា បន្ថែមពីលើទ្រព្យសម្បត្តិដោយឡែក សហព័ទ្ធនីមួយៗ មានសិទ្ធិទទួលយក ១ភាគ២ នៃទ្រព្យសម្បត្តិរួម។ ប៉ុន្តែបើមានករណីពិសេស និងមានការទាមទាររបស់ប្ដីប្រពន្ធណាម្ខាង តុលាការក៏អាចបែងចែកទ្រព្យសម្បត្តិ ដោយពិចារណាទៅលើស្ថានភាពផ្សេងៗដូចជា ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗ ទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗចំពោះលទ្ធកម្មនៃទ្រព្យសម្បត្តិ ការថែរក្សា ឬការបង្កើនទ្រព្យ អំឡុងពេលអាពាហ៍ពាហ៍ កម្រិតជីវភាពរស់នៅក្នុងពេលមានចំណងអាពាហ៍ពិពាហ៍ អាយុ ស្ថានភាពផ្លូវចិត្ត និងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗ និងផលប្រយោជន៍របស់កូនជាអាទិ៍។

ឃើញថា ទោះបីជាពេលចាប់ផ្ដើមអាពាហ៍ពិពាហ៍ដំបូងដើមចោទពុំបានធ្វើការរកស៊ីក៏ដោយ តែមាត្រា ៩៨០ កថាខណ្ឌទី៣ បានចែងថា គេហកិច្ច ត្រូវចាត់ទុកថាមានតម្លៃស្មើនឹងការងារដែលធ្វើក្រៅផ្ទះដែរ។ តុលាការយល់ឃើញថា ផ្ទះដែលដើមចោទទាមទារ គឺមានទំហំធំជាងដី និងផ្ទះដែលដើមចោទសុំប្រគល់ឲ្យចុងចម្លើយ តែដើមចោទជាស្ត្រី និងត្រូវចិញ្ចឹមបីបាច់ មើលថែរក្សាកូនប្រុសស្រី គប្បីមានទីជម្រកសមរម្យ និងសុវត្ថិភាពដល់កូនៗ ហេតុនេះ ដើម្បីជាប្រយោជន៍របស់កូនផង តុលាការគប្បីពិចារណា និងសម្រេចឲ្យដើមចោទទទួលបានកម្មសិទ្ធិលើដី និងផ្ទះមួយកន្លែង មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ 17100602-2889 ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ស្ថិតនៅភូមិខ្នារ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប ហើយឲ្យចុងចម្លើយទទួលបានកម្មសិទ្ធិលើដី និងផ្ទះ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ 171006002-3006 ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ស្ថិតនៅភូមិខ្នារ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរា, សាឡុងឈើបេងមួយឈុត, តុបាយចំនួន ០១ និងកៅអីតុកតា ចំនួន ០៨ គ្រាប់, ម៉ូតូមួយគ្រឿងម៉ាកហុងដាឌ្រីម ផលិតឆ្នាំ២០១៤ ពណ៌ខៀវ និងកាមេរ៉ាថតរូបម៉ាកកាណុង ០៧គ្រឿង និងម៉ាកនីកុង ចំនួន ០២ គ្រឿង ដែលមាននៅក្នុងហាងលក់ដូរ ស្ថិតនៅភូមិសាលាកំរើក សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប។

**៩**-ដើមចោទទាមទារបែងចែកបំណុលរួមមាន ប្រាក់ជំពាក់ឪពុកម្ដាយរបស់ដើមចោទចំនួន ៧.៥០០$ (ប្រាំពីរពាន់ប្រាំរយ)ដុល្លារអាមេរិក និងប្រាក់ជំពាក់ឈ្មោះ [redacted] ថាយ និងប្រពន្ធឈ្មោះ [redacted] យីងហ្វង ចំនួន ៨.០០០$ (ប្រាំបីពាន់ដុល្លារអាមេរិក) ជាពីរចំណែកស្មើគ្នា គឺចុងចម្លើយបានទទួលស្គាល់ ហេតុនេះ តុលាការគប្បីសម្រេចទទួលស្គាល់ការទាមទាររបស់ដើមចោទ។

**១០**-ដើមចោទទាមទារឲ្យចុងចម្លើយជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្ដី ចុងចម្លើយក៏ទទួលស្គាល់ការទាមទារនេះដែរ ហេតុនេះ តុលាការគប្បីសម្រេចឲ្យចុងចម្លើយជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្ដី ស្របទៅតាមមាត្រា ៦៤ និងមាត្រា ៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## សេចក្ដីសម្រេចបញ្ចប់

១-ឱ្យដើមចោទឈ្មោះ [redacted] យីន លែងលះពីចុងចម្លើយឈ្មោះ [redacted] ហ្វាយ ចាប់ពីពេលនេះតទៅ។

២-ឱ្យដើមចោទឈ្មោះ [redacted] យីន ជាអ្នកមានអំណាចមេបាលើកូន០២នាក់មានឈ្មោះ [redacted] សានលី ភេទស្រី កើតថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៧ និងឈ្មោះ [redacted] សម្បត្តិ ភេទប្រុស កើតថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៤។



Scanned with CamScanner

-ទុកសិទ្ធិឱ្យចុងចម្លើយចូលជួបប្រាស្រ័យទាក់ទងនឹងកូននៅពេលថ្ងៃបានគ្រប់ពេលវេលា ដើម្បីពិនិត្យមើលស្ថានភាពកូន ដោយដើមចោទមិនត្រូវរារាំងកូនមិនឱ្យមានការប្រាស្រ័យទាក់ទងជាមួយចុងចម្លើយឡើយ ។ យោងតាម មាត្រា ១០៤០ និង មាត្រា ១០៤១ នៃក្រមរដ្ឋប្បវេណី ។

៣.ឲ្យចុងចម្លើយឈ្មោះ [redacted] ហ្វាយ បង់ថ្លៃអាហារកាតព្វកិច្ចចិញ្ចឹមកូនទាំងពីរតាមលទ្ធភាពរហូតដល់កូនមាននីតិភាព។

៤.បែងចែកទ្រព្យសម្បត្តិរួមដូចខាងក្រោម៖

ក.ដើមចោទទទួលបានជាកម្មសិទ្ធិលើ ដី និងផ្ទះមួយកន្លែង មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ 17100602-2889 ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ស្ថិតនៅភូមិខ្វារ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប។

ខ.ចុងចម្លើយទទួលបានជាកម្មសិទ្ធិរួមមាន៖

-ដី និងផ្ទះ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ 171006002-3006 ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ស្ថិតនៅភូមិខ្វារ សង្កាត់ជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប។

-សាឡុងឈើបេងមួយឈុត, តុបាយចំនួន ០១ និងកៅអីតុកតា ចំនួន ០៨ គ្រាប់។

-ម៉ូតូមួយគ្រឿងម៉ាកហុងដាឌ្រីម ផលិតឆ្នាំ២០១៤ ពណ៌ខៀវ និងកាមេរ៉ាថតរូបម៉ាកកាណុង ០៧គ្រឿង និងម៉ាកនីកុង ចំនួន ០២ គ្រឿង ដែលមាននៅក្នុងហាងលក់ដូរ ស្ថិតនៅភូមិសាលាកំរើក សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប។

៥.ឲ្យដើមចោទ និងចុងចម្លើយទទួលបន្ទុកសងបំណុលរួមសរុបចំនួន ១៥៥០០$ (មួយម៉ឺនប្រាំពាន់ប្រាំរយដុល្លារអាមេរិក) ជាពីរចំណែកស្មើគ្នា។

៦.ឲ្យចុងចម្លើយទទួលបន្ទុកប្រាក់ប្រដាប់ក្តី។

-សាលក្រមនេះ បានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសជាសាធារណៈចំពោះមុខដើមចោទឈ្មោះ [redacted] យីន ដោយមានលោកមេធាវី [redacted],លោកមេធាវី [redacted] និងលោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិ និងចុងចម្លើយឈ្មោះ [redacted] ហ្វាយ ដែលមានលោកមេធាវី [redacted], លោកមេធាវី [redacted] លោកមេធាវី [redacted] និងលោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិ។

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted]

បានឃើញ
ថ្ងៃព្រហស្បតិ៍ ៦រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៩
**ចៅក្រមជំនុំជម្រះ**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃព្រហស្បតិ៍ ៦រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
សៀមរាប,ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៩
**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner